00888438

E218/7/1/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Feb-2013, 13:00
CMS/CFO: Sann Rada

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កំណត់ឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E218/7/1 | 00886888-00886904 | 19 Feb 2013 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| លុបលេខជើងទំព័រ មានកំហុសឆ្គងនៅក្នុងលេខជើងទំព័រ កែសំរួលខ្លឹមសារខ្លះៗ និងកែប្រែកថាខណ្ឌទី១០ |

**សេចក្តីលម្អិតនៃការកែតម្រូវ៖**

- នៅក្នុងកថាខណ្ឌទី៣ ធ្វើការកែប្រែ "ការរៀបចំមណ្ឌលឯកសារ សារមន្ទីរបណ្ណសារដ្ឋាន និងបណ្ណាល័យ " ជា "ការតាំងពិពណ៌" និងបន្ថែមនូវពាក្យ "គម្រោង" ពីមុខពាក្យ "ស្តូបសំរាប់រំលឹកជាសាធារណៈ"នៅក្នុងចំនុចទី១ នៃកថាខណ្ឌទី៣។

- នៅក្នុងកថាខណ្ឌទី១០ ធ្វើការកែប្រែពី "ក្រោយពីមានការប្រឹក្សាយោបល់ជាច្រើនដងលើបញ្ហានេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើន បានធ្វើការស្នើសុំក្នុងនាមកូនក្តីរបស់ខ្លួននូវកាលបរិច្ឆេទចំនួនពីរសម្រាប់ទិវារំលឹក ការចងចាំ គឺថ្ងៃ១៧ មេសា ឬថ្ងៃ២០ ឧសភា ដោយកាលបរិច្ឆេទទាំងពីរនេះនឹងត្រូវដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា។" ប្តូរទៅជា "សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងធ្វើកិច្ចពិគ្រោះយោបល់ចុងក្រោយលើកាលបរិច្ឆេទសំរាប់ថ្ងៃចងចាំដែលត្រូវស្នើទៅរដ្ឋាភិបាលក្នុងនាមកូនក្តីរបស់ខ្លួន។"

-ក្រោម កថាខណ្ឌទី១០ បន្ថែមពាក្យ "គម្រោង"ពីមុខពាក្យ "ស្តូបសំរាប់រំលឹកជាសាធារណៈ"

- កថាខណ្ឌទី១៤ លុបចោលជើងទំព័រលេខ៦ និងកថាខណ្ឌទី២១ លុបចោលនូវជើងទំព័រលេខ៧

- ជើងទំព័រលេខ៨កែ "ឧបសម្ព័ន្ធxxx" ជា "ឧបសម្ព័ន្ធA"កម្មវិធីសំណង២០១៣-២០១៧ របស់អង្គភាពគាំពារជនរងគ្រោះ""។

- ជើងទំព័រលេខ៩ កែ "ឧបសម្ព័ន្ធxxx "ជា "ឧបសម្ព័ន្ធ B
"សេចក្តីលំអិតអំពីគម្រោងអាទិភាពទាំង៦របស់អង្គភាពគាំពារជនរងគ្រោះ""

- ជើងទំព័រលេខ១០កែ "ឧបសម្ព័ន្ធxx" ជាឧបសម្ព័ន្ធC
"ការតស៊ូមតិក្នុងការរៃអង្គាសមូលនិធិរបស់អង្គភាពគាំពារជនរងគ្រោះ"

- ឧបសម្ព័ន្ធ១២ កែ “ឧបសម្ព័ន្ធឃ” ជា “ឧបសម្ព័ន្ធD” “ឧបសម្ព័ន្ធ ង ” កែជា “ឧបសម្ព័ន្ធE” និងលេខជើងទំព័រ១៣ កែ “ឧបសម្ព័ន្ធច ” ជា “ឧបសម្ព័ន្ធ F”
- នៅក្នុងកថាខណ្ឌទី៣២ លុបចោលពាក្យ “ជាមួយអង្គភាពគាំពារជនរងគ្រោះ”

ស្នើដោយ៖ [illegible] ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

00888440

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស/បកប្រែជាភាសាខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការចូលបញ្ជាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូងអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤)) (មានភ្ជាប់ឧបសម្ព័ន្ធសម្ងាត់)**

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

**<u>នៅចំពោះមុខ៖</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

**<u>ផ្ញើជូន៖</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
គង់ ពិសី
គង់ ផល្លះ
យុង ផានិត
សំ សុគង់
វ៉ែន ពៅ
ទី ស្រីនណា
Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Beini YE
Elodie DULAC
Pascal AUBOIN

ជា លាង
Andrew T. CAYLEY
យ៉ែត ចរិយា
William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន
អៀង សារី
នួន ជា

**<u>សហមេធាវីការពារក្ដី៖</u>**

សុន អរុណ
Victor KOPPE

អាង ឧត្ដម
Michael G. KARNAVAS

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGES

*ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូងអំពីគម្រោង*
*ជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤))*
Original EN: 00882287-00882300

00888442

I. ប្រវត្តិនីតិវិធី និងសេចក្តីផ្តើម

1. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ប្រធានអង្គជំនុំជម្រះសាលាដំបូង បានចេញ អនុស្សរណៈមួយស្តីពី *ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤))*[1] ដោយស្នើឱ្យសហមេធាវីនាំមុខកំណត់អំពីបញ្ជីគម្រោងសំណងជាអាទិភាព ដែលបច្ចុប្បន្នកំពុងត្រូវបានរៀបចំដើម្បីដាក់ជូនមកអង្គជំនុំជម្រះ។ លើសពីនេះទៀត ប្រធានអង្គជំនុំជម្រះបានស្នើឱ្យសហមេធាវីនាំមុខ ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្នអំពីការផ្តល់ហិរញ្ញវត្ថុដល់គម្រោងជាអាទិភាពរបស់ពួកគេ ដោយមានការប្រឹក្សាយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ។ នៅពេលបច្ចុប្បន្ន សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសម្រេចធ្វើការរៀបចំសំណងជាគម្រោងដែលនឹងត្រូវអនុវត្ត ដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបួន* ៣(ខ)។

2. នៅខែឧសភា ឆ្នាំ២០១១ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ បានរៀបចំសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅជាគម្រោង ឬប្រភេទគម្រោងនៃសំណងចំនួន ១៦ គម្រោង[2]។ យើងបានឈានមកដល់គម្រោងទាំងនេះបន្ទាប់ពីបានធ្វើការវិភាគ និង ពិចារណាដោយយកចិត្តទុកដាក់លើសំណូមពរដែលបានបញ្ជាក់ដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពាក្យសុំរបស់ពួកគេ ក៏ដូចជាតាមរយៈការប្រឹក្សាយោបល់ជាច្រើនដែលបានធ្វើឡើងដោយ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគ្នាឯង។ លើសពីនេះទៀត មានការប្រឹក្សាយោបល់បន្ថែមនៅក្នុងខែមីនា ឆ្នាំ២០១២ ដែលបាននាំឱ្យមានការរៀបចំជាអាទិភាពនៃប្រភេទគម្រោងទាំងអស់នេះ និងសំណើពីសហមេធាវីនាំមុខ និងសហមេធាវីតំណាងដើម

[1] ឯកសារ E218/7 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងក្រោមចំណងជើងថា "ការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤))។

[2] "គម្រោងសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងស្នើសុំក្នុងបណ្តឹងទាមទារចុងក្រោយ" មានភ្ជាប់ក្នុងឧបសម្ព័ន្ធ G។

បណ្តឹងរដ្ឋប្បវេណីជូនទៅអង្គភាពគាំពារជនរងគ្រោះសុំកិច្ចសហការ និងជំនួយបន្ថែម ជាពិសេសក្នុងផ្នែករៃអង្គាសមូលនិធិ។ ក្នុងអំឡុងពេលនេះ សមាសភាពសំខាន់ៗនៃគម្រោងទាំងអស់នេះត្រូវបានបរិយាយល្អិតល្អន់ថែមទៀត តាមរយៈកិច្ចប្រជុំសហការគ្នា សិក្ខាសាលា និងសន្និសីទជាច្រើន ដែលបានធ្វើលើប្រធានបទនៃសំណងទាំងអស់នេះ ក្នុងមានគោលបំណងធានាឱ្យមានគម្រោងសំណងដ៏មានប្រសិទ្ធភាព និងប្រកបដោយអត្ថន័យសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២/០១ ស្របជាមួយនឹងលក្ខណវិនិច្ឆ័យតាមផ្លូវច្បាប់ ដែលបានកំណត់ដោយតុលាការ។

3. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ សហ-មេធាវីនាំមុខបានចង្អុលបង្ហាញជូនអង្គជំនុំជម្រះថា គម្រោងចំនួន ៦ ត្រូវបានកំណត់ថាជាគម្រោងអាទិភាព[3]។ ទោះបីជាយ៉ាងនេះក្តី គម្រោងមួយក្នុងចំណោមនេះ ដែលស្តីពីការ<u>តាំងពិពណ៌</u> ~~អៀបចំមណ្ឌលឯកសារ សារមន្ទីរ បណ្ណាសាដ្ឋាន និងបណ្ណាល័យ~~ ត្រូវបានបំបែកចេញជាគម្រោងពីរផ្សេងគ្នា។ ដោយមូលហេតុនេះហើយ យើងមានគម្រោងសំណងជាអាទិភាពចំនួន ៧ ដែលត្រូវបានបែងចែក ចេញជាបីជំពូកធំៗដូចខាងក្រោម៖

- ជំពូកនៃការរំលឹក និងការគោរពវិញ្ញាណក្ខន្ធ មាន២គម្រោងសំណងគឺ *ទិវាចងចាំ* និង<u>គម្រោង</u>*ស្តូបសម្រាប់រំលឹកជាសាធារណៈ*។
- ជំពូកនៃការស្តារនីតិសម្បទាមានពីរគម្រោងគឺ *វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម* និង *ក្រុមជួយខ្លួនឯង*។ និង
- ជំពូកនៃចងក្រងឯកសារ-ការអប់រំមានបីគម្រោងគឺ *សៀវភៅស្តីពីការចូលរួមរបស់ជនរងគ្រោះ និងការជម្លៀសដោយបង្ខំ ពិធីតាំងពិពណ៌ជាអចិន្ត្រៃយ៍* និង *គម្រោងតាំង ពិពណ៌ និងអប់រំចល័ត*។

4. គម្រោងជាអាទិភាពទាំង ៧ នេះ កំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំចុងក្រោយ ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គការជាដៃគូនានា។ អង្គការជាដៃគូទាំងអស់ដែលបានបញ្ជាក់ការចូលរួមរបស់គេ បានគូសបញ្ជាក់អំពីគោលបំណងរបស់ខ្លួនក្នុងការទទួលខុសត្រូវចំពោះការអនុវត្តគម្រោងទាំងអស់នេះ និងក្នុងការធ្វើកិច្ចព្រមព្រៀងផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ជាមួយនឹងម្ចាស់ជំនួយ និង/ឬ អង្គភាពគាំពារជនរងគ្រោះ។

---

[3] ឯកសារ E1/114.2 ប្រតិចារឹកស្តីពីកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៧-៨។
*ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូងអំពីគម្រោង*
*ជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤))*
Original EN: 00882287-00882300

ថ្មីៗនេះ និងតាមការផ្ដួចផ្ដើមរបស់សហមេធាវីនាំមុខ គម្រោងទាំងអស់នេះត្រូវបានពិភាក្សាគ្នាបន្ថែម និងមានការកំណត់ផែនការច្បាស់លាស់មួយក្នុងការបញ្ចប់ការរៀបចំផែនការគម្រោងទាំងនេះដោយសហការជាមួយអ្នកជំនាញផ្ដល់ប្រឹក្សាដែលអង្គភាពគាំពារជនរងគ្រោះបានជួល។ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានបន្តចូលរួមនៅក្នុងដំណើរការនេះ ដើម្បីធានាថាការរៀបចំផែនការគម្រោងចុងក្រោយសមស្រប តាមសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងតាមរបបសំណងដែលបានកំណត់ដោយតុលាការ។

5. នៅពេលដែលការវិវឌ្ឍនៃគម្រោងសំណងទាំងឡាយបានកើនឡើង គម្រោងមួយចំនួនត្រូវបានបញ្ចូលគ្នា ឬរៀបចំឡើងវិញ ដើម្បីឲ្យរឹតតែសមស្របតាមសេចក្ដីត្រូវការ និងការចង់បានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសមត្ថភាព និងធនធាននៃដៃគូគម្រោងនានាផងដែរ។ បន្ថែមពីលើគម្រោងជាអាទិភាពទាំង ៧ ដែលបានបញ្ជាក់នៅពេលនេះ នៅមានគម្រោងចំនួន ៦ បន្ថែមទៀតដែលសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញជូនអង្គជំនុំជម្រះនៅក្នុងពេលសវនាការបឋមស្ដីពីការកំណត់ជាក់លាក់នូវសំណង[4]។ គម្រោងទាំងអស់នេះកំពុងស្ថិតក្នុងការពិចារណានៅឡើយ ប៉ុន្តែស្ថិតនៅលំដាប់ទីពីរបន្ទាប់ពីក្រុមគម្រោងជាអាទិភាព។ ប្រសិនបើពេលវេលា និងធនធានអនុញ្ញាតសម្រាប់ការបង្កើត និងការផ្ដល់ហិរញ្ញវត្ថុដល់គម្រោងទាំងនេះបានគ្រប់គ្រាន់ យើងនឹងធ្វើការពិចារណាបញ្ចូលគម្រោងមួយ ឬលើសពីនេះ ក្នុងចំណោមគម្រោងទាំងអស់នេះនៅក្នុងការទាមទារសំណងចុងក្រោយ។

6. នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃកិច្ចដំណើរការនីតិវិធី ក្នុងករណី ០០២/០១ ដែលក្នុងនោះការបំបែកដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងករណីនេះត្រូវបានចាត់ទុកជាមោឃៈ[5]។ ផ្អែកតាមសេចក្ដីសម្រេចនេះ និងដោយយោងទៅលើស្ថានភាពថាវិសាលភាពនីតិវិធីនឹងត្រូវកំណត់ជាថ្មីដោយអង្គជំនុំជម្រះសាលាដំបូង និងដោយយោងលើចន្លោះពេលខ្លីរវាងការចេញសេចក្ដីសម្រេច និងកាលបរិច្ឆេទសម្រាប់ដាក់សារណានេះ សហមេធាវីនាំមុខ

---

[4] *សូមមើល*ឯកសារ E1/6.1ប្រតិចារឹកនៃសវនាការបឋម ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ និងឯកសារ E1/11.1 ប្រតិចារឹកនៃសវនាការស្ដីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១។

[5] សូមមើលសេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCC-TC/SC(18) ឯកសារលេខ E163/5/1/13, ចុះថ្ងៃទី៨ កុម្ភៈ ២០១៣។

និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី រក្សាសិទ្ធិក្នុងការកែតម្រូវបន្ទាប់ទៅលើសំណើរទាក់ទងនឹងសំណង ស្របតាមការកំណត់ចុងក្រោយលើវិសាលភាពនៃសំណុំរឿង ០០២/០១ នៅពេលដែលការកំណត់នោះត្រូវបានធ្វើឡើង។

II. គម្រោងសំណងជាអាទិភាព

ជំពូកទី១៖ ការរំលឹក និងការគោរពវិញ្ញាណក្ខន្ធ

***គម្រោងទី ១៖ ទិវារំលឹកការចងចាំ***

7. ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យបង្កើតទិវារំលឹកការចងចាំ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលជាផ្លូវការ ដើម្បីផ្តល់កិត្តិយសដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ទាំងអ្នកនៅរស់រានមានជីវិត ទាំងអ្នកបាត់បង់ជីវិត និងជាការទទួលស្គាល់ឧក្រិដ្ឋកម្មទាំងឡាយនៃរបបនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានលើកឡើងថា ទិវានោះគួរតែផ្សេងពីថ្ងៃឈប់សម្រាកជាតិប្រចាំឆ្នាំនានាដែលកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។ ហេតុដូច្នេះ គម្រោងសំណងនេះផ្តោតទៅលើការកំនត់ថ្ងៃឈប់សម្រាកថ្មីមួយដោយរាជរដ្ឋាភិបាលកម្ពុជា។ កាលបរិច្ឆេទជាច្រើនត្រូវបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹងត្រូវបង្ហាញជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការពិចារណា និងសម្រេច។

8. ការបង្កើតទិវារំលឹកការចងចាំដូចនេះ ត្រូវបានស្នើឡើងដើម្បីទទួលបាននូវការទទួលស្គាល់ជាផ្លូវការ និងអចិន្ត្រៃយ៍ និងលើកកម្ពស់ការចងចាំរួមនូវឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម។ វានឹងជួយស្តារកិត្តិយស និងព្យាបាលព្យសនកម្មផ្លូវចិត្តដែលជនរងគ្រោះដោយសាររបបខ្មែរក្រហមបានជួបប្រទះ ដោយសារតែឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានកាត់សេចក្តីនៅក្នុងសំណុំរឿង ០០២ ជាពិសេសជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី។ ជាទម្រង់និមិត្តរូបនៃសំណង ការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃសំណងនេះមិនត្រូវផ្តល់ឱ្យតែចំពោះដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ តែវានឹងផ្តល់ប្រយោជន៍ជាចាំបាច់ទៅដល់ជនរងគ្រោះទាំងឡាយ និងសង្គមកម្ពុជាជាទូទៅផងដែរ។ ឧទាហរណ៍មួយទៀតនៃតួនាទីទាំងពីរនេះ គឺតួនាទីនៃទិវារំលឹកការចងចាំនៅក្នុងការអប់រំដល់សាធារណជនអំពីឧក្រិដ្ឋកម្មនានានៃរបបខ្មែរក្រហម និងនៅក្នុងការការពារមិនឱ្យឧក្រិដ្ឋកម្មនេះកើតមានឡើងសារជាថ្មីនៅក្នុងប្រទេសកម្ពុជា។

9. ការប្រឹក្សាយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញឱ្យឃើញច្បាស់ថា ពួកគេស្នើសុំយ៉ាងជាក់លាក់ ឱ្យមានថ្ងៃឈប់សម្រាកប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលជាផ្លូវការនៅទូទាំងប្រទេស។

ដោយសារតែទិវាចងចាំបែបនេះតម្រូវឲ្យមានការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ផ្នែកសហមេធាវីនាំមុខ ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងអង្គការជាដៃគូនានា កំពុងដំណើរការទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានទៅដល់មានការទទួលស្គាល់ទិវានេះពីរាជរដ្ឋាភិបាលកម្ពុជា។

10. ~~ក្រោយពីមានការប្រឹក្សាយោបល់ជាច្រើនដងលើបញ្ហានេះ~~ សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងធ្វើកិច្ចពិគ្រោះយោបល់ចុងក្រោយលើកាលបរិច្ឆេទសំរាប់ថ្ងៃចងចាំដែលត្រូវស្នើទៅរដ្ឋាភិបាល~~គាត់ច្រើនក្នុងនាមកូនក្តីរបស់ខ្លួន។ បានធ្វើការស្នើសុំក្នុងនាមកូនក្តីរបស់ខ្លួននូវកាលបរិច្ឆេទចំនួនពីរសម្រាប់ទិវារំលឹក ការចងចាំ គឺថ្ងៃ១៧ មេសា ឬថ្ងៃ២០ ឧសភា ដោយកាលបរិច្ឆេទទាំងពីរនេះនឹងត្រូវដាក់ជូនរាជរដ្ឋា ភិបាលកម្ពុជា។~~

***គម្រោងទី ២៖ គម្រោងស្តូបសម្រាប់ការរំលឹកជាសាធារណៈ***

11. *គម្រោងស្តូបសម្រាប់ការរំលឹកជាសាធារណៈ* ស្នើសុំឲ្យមានការវិវឌ្ឍ និង/ឬ បង្កើតបូជនីយដ្ឋានសាធារណៈពី៣ កន្លែង ទៅ ៦ កន្លែង ដែលបានបែងចែកតាមភូមិសាស្ត្រនៅ ទូទាំងប្រទេសកម្ពុជា និងត្រូវបានជ្រើសរើសផ្អែកលក្ខណវិនិច្ឆ័យមួយចំនួន ដែលមានបំណងធានា ថាទីកន្លែងទាំងនេះអាចឲ្យគេទៅដល់បាន អាចរក្សាបាន និងសាងសង់ដោយផ្អែកតាមធនធាន និងសមត្ថភាពដែលអាចធ្វើទៅកើត។ សមាសភាពសំខាន់ៗនៃគម្រោងសំណងនេះគឺការរៀបចំផែន ការ និងការសាងសង់បូជនីយដ្ឋានសាធារណៈនានា រួមទាំងផ្នែកអប់រំផងដែរ ដើម្បីជូនដំណឹងដល់សាធារណជនអំពីសារៈសំខាន់ និងបរិបទជាប្រវត្តិសាស្ត្រពាក់ព័ន្ធទៅនឹងការចងចាំ រួមមានសកម្មភាពផ្សព្វផ្សាយ និងអប់រំដែលនឹងធ្វើឲ្យសាធារណជនមានការយល់ដឹង និងបង្កើតអោយមានការជួបសន្ទនាបង្ហាញបទពិសោធន៍ទាំងឡាយក្នុងរបបខ្មែរក្រហម និងមានយុទ្ធនាការផ្តល់ព័ត៌មានជាសាធារណៈ ដើម្បីផ្សព្វផ្សាយអំពីអត្ថិភាព និងគោលបំណងនៃបូជនីយដ្ឋានទាំងអស់នេះ។

12. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនក្នុងសំណុំរឿង ០០២ បានលើកឡើងអំពីបូជនីយដ្ឋានសាធារណៈថាជាទម្រង់នៃសំណងដែលគេចង់បាន។ ការបង្កើតបូជនីយដ្ឋានសាធារណៈដែលអាចទៅដល់ដែលពោរពេញដោយអត្ថន័យ និងមានការថែទាំបានល្អ នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្តារសង្គមកម្ពុជា។ បូជនីយដ្ឋានទាំងនេះនឹងទទួលស្គាល់ជាសាធារណៈអំពីការឈឺចាប់ផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយតាមរយៈការធ្វើដូច្នេះ ក៏នឹងបំពេញមុខងារក្នុងការផ្តល់ សំណងនៅក្នុងការព្យាបាលផ្លូវចិត្តជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបានទទួលរងនូវអំពើឃោរឃៅ

និងការផ្សះផ្សាប្រទេសកម្ពុជាទាំងមូលផងដែរ។ បូជនីយដ្ឋានទាំងនោះផ្តល់ជាទីកន្លែងដ៏សំខាន់ សម្រាប់គោរពដល់ជនរងគ្រោះដែលបាត់បង់ជីវិត និងជនរងគ្រោះដែលនៅរស់រានមានជីវិត ជាពិសេសគឺដើមបណ្តឹងរដ្ឋប្បវេណី។ ទីតាំងនេះមានតួនាទីជាអ្នករំលឹកជានិរន្តរ៍ពីអំពើ ឃោរឃៅរបស់ខ្មែរក្រហម ជាពិសេសគឺការជម្លៀសប្រជាជនដោយបង្ខំ ហើយជួយធានាថអំពើ នេះនឹងមិនកើតមានសារជាថ្មីទៀត បង្កើត និងរក្សាទុកប្រវត្តិសាស្ត្រនៃរបបនេះ និងលើកតម្កើងការពិភាក្សាពីមួយជំនាន់ទៅមួយជំនាន់ ដែលបង្កើនចំណងទាក់ទងគ្នាក្នុងសង្គម និងលុបបំបាត់ ស្លាកស្នាមព្យសនកម្មទាំងឡាយដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង។

13. តាមរយៈដំណើរការដែលមានការចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការងារជាមួយអង្គភាពគាំពារជនរងគ្រោះ និងអង្គការសង្គមស៊ីវិលជាដៃគូក្នុងការបង្កើតគម្រោងនេះ។ អង្គការក្តីករុណា និង យុវជនដើម្បីសន្តិភាព ដែលមានបទពិសោធន៍ច្រើននៅក្នុងការបង្កើតបូជនីយដ្ឋានដែលមាននិរន្តរភាព តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសហគមន៍ នឹងដើរតួនាទីជាដៃគូអនុវត្តសម្រាប់គម្រោងនេះ។ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) នឹងធ្វើជា ដៃគូលើគម្រោងនេះនៅក្នុងផ្នែកផ្តល់ប្រឹក្សាជួយឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ កំពុងស្ថិតនៅក្នុងដំណើរការទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយសម្រួលដល់កិច្ចសហការលើគម្រោងនេះ ជាពិសេសជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ និងស្ថាប័នរាជរដ្ឋាភិបាលនៅមូលដ្ឋាននានា។ នៅពេលដែល និងលុះត្រាតែមានការឯកភាពនេះ ទើបដើមបណ្តឹងរដ្ឋប្បវេណីនឹងបញ្ចប់ការរៀបចំគម្រោងទាំងនេះ និងស្នើសុំឱ្យតុលាការទទួលស្គាល់គម្រោងនេះជាគម្រោងសំណង ដែលមានការសហការយ៉ាងពេញលេញ និងការព្រមព្រៀងពីរាជរដ្ឋាភិបាលកម្ពុជា។

ជំពូកទី២៖ ការស្តារនីតិសម្បទា

14. ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានស្នើសុំឱ្យមានសេវាថែទាំសុខភាពផ្លូវចិត្ត ដោយចាត់ទុកសេវានេះថាជាទម្រង់មួយនៃសំណង។ ការសិក្សាថ្មីៗនេះបង្ហាញពីចំនួនជនរងគ្រោះជាច្រើននាក់ ដែលទទួលរងជំងឺតានតឹងក្នុងអារម្មណ៍ក្រោយមានការប៉ះទង្គិចធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ដែលជាការពិតរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ គម្រោងដែលបំពេញបំណងប្រាថ្នាឱ្យមានការគាំទ្រផ្លូវចិត្តបែបនេះ ត្រូវបានបង្កើតឡើងតាមវិធីមួយដែលថា គម្រោងនេះអាចត្រូវបានអង្គជំនុំជម្រះ

សាលាដំបូងកំណត់ថាជាសំណងជាសមូហភាព និងសំណងផ្លូវចិត្ត នៅក្នុងសំណុំរឿង ០០២/០១។ គម្រោងចំនួនពីរកំពុងត្រូវបានបង្កើតឡើងជាប្រភេទនៃការស្តារនីតិសម្បទាៈ *ការផ្តើមគំនិតសម្រាប់ឱ្យមានវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ និងក្រុមជួយខ្លួនឯងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២*។ សម្រាប់គម្រោងទាំងពីរនេះ សហមេធាវីនាំមុខកំពុងចាប់ដៃគូជាមួយអង្គការ ចិត្តសង្គមអន្តរវប្បធម៌ (TPO) ដែលនឹងធ្វើការទទួលខុសត្រូវចំពោះការអនុវត្តគម្រោងនេះ។ TPO បានបំពេញការងារអស់រយៈពេលជាច្រើនឆ្នាំកន្លងមកជាមួយដើមបណ្តឹង[6] និងជាអង្គការមិនមែនរដ្ឋាភិបាលតែមួយគត់ដែលផ្តល់ការគាំទ្រផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។

***គម្រោងទី ៣៖ វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម***

15. វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម មានគោលបំណងផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នូវការព្យាបាលជម្ងឺផ្លូវចិត្តដែលមានប្រសិទ្ធភាព ដោយសារតែវិធីនេះដោះស្រាយដោយផ្ទាល់ចំពោះការឈឺចាប់ផ្លូវចិត្តរបស់ជនរងគ្រោះ ដែលកើតឡើងដោយសារឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តលើពួកគេ។

16. វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មគឺជាវិធីព្យាបាលជម្ងឺផ្លូវចិត្តមួយប្រភេទ ដែលមានប្រសិទ្ធភាពក្នុងរយៈពេលខ្លី។ វិធីព្យាបាលនេះមានគោលបំណងជាក់លាក់សម្រាប់ជួយជនរងគ្រោះនៃអំពើហិង្សាគាំទ្រដោយរដ្ឋ។ នៅក្នុងដំណាក់កាលដំបូងនៃវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មដូចដែលធ្លាប់បានអនុវត្តដោយអង្គការ TPO ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ នឹងត្រូវបានអញ្ជើញឱ្យមករៀបរាប់អំពីបទពិសោធន៍ដ៏ឈឺចាប់របស់ខ្លួន ហើយដោយមានការសហការជាមួយនឹងបុគ្គលិកវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្ត។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនឹងរំលឹកនូវការចងចាំដ៏ឈឺចាប់របស់ខ្លួន និងបង្កើតវាឱ្យទៅជាឯកសារជាលាយលក្ខណ៍អក្សរមួយហៅថា *សក្ខីកម្ម*។ ការចងក្រងការចងចាំដ៏ឈឺចាប់នៅក្នុងកន្លែងមួយដែលមានសុវត្ថិភាព និងតាមរយៈការជួយជ្រោមជ្រែងពីបុគ្គលិកសុខភាពផ្លូវចិត្តដែលត្រូវបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវបែបនេះ នឹងផ្តល់លទ្ធភាពឱ្យដើមបណ្តឹងរដ្ឋប្បវេណីរំលឹកបទពិសោធន៍ដ៏ឈឺចាប់របស់ខ្លួន។

---

[6] ~~ឈ្មោះគម្រោងដែល TPO កំពុងបំពេញការងារជាមួយដើមបណ្តឹងរដ្ឋប្បវេណី។~~

*ការចង្អុលបង្ហាញរបស់សហមេធាវីនាំមុខជូនដល់អង្គជំនុំជម្រះសាលាដំបូងអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ ស្ទួន(៤))*

Original EN: 00882287-00882300

17. នៅក្នុងដំណាក់កាលទីពីរ សក្ខីកម្មទាំងនេះនឹងត្រូវបានអានឮៗ និងប្រគល់ជូនឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីក្នុងពិធីបុណ្យជាតិមួយស្របតាមអបិយជំនឿ/ជំនឿសាសនា និងទំនៀមទម្លាប់វប្បធម៌របស់ភាគីនីមួយៗ។ ពិធីបុណ្យជាតិនេះនឹងត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា ទាំងនៅក្នុង ឬ នៅជិតសហគមន៍ដែលដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅ ហើយនឹងមានទាំងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ្នករស់រានមានជីវិត សាច់ញាតិ សមាជិកសហគមន៍ មេដឹកនាំសាសនា ព្រមទាំងអ្នកតំណាងមកពីភ្នាក់ងាររដ្ឋាភិបាល និងភ្នាក់ងារមិនមែនរដ្ឋាភិបាលផងដែរ។

18. ផលប្រយោជន៍នៃវិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មនេះ សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដូចបានរៀបរាប់ដោយអង្គការ TPO មានច្រើនយ៉ាង។ ការព្យាបាលតាមវិធីនេះនឹងផ្ដល់លទ្ធភាពឲ្យជនរងគ្រោះរៀបរាប់ និងរំលឹកបទពិសោធន៍ដ៏ឈឺចាប់ ស្ដារកិត្តិយសរបស់ខ្លួនឡើងវិញ ចងក្រងការរំលោភសិទ្ធិមនុស្សទុកជាឯកសារ និងតស៊ូមតិដើម្បីឲ្យមានការឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍សម្រាប់ខ្លួននៅក្នុងស្ថានការណ៍នៃដំណើរការផ្សះផ្សា និងដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា។

***គម្រោងទី ៥៖ ក្រុមជួយខ្លួនឯង***

19. ក្រុមជួយខ្លួនឯងគឺជាវិធីព្យាបាលមួយផ្សេងទៀតដែលអង្គការ TPO កំពុងតែបង្កើតឡើង។ វិធីព្យាបាលនេះមានគោលបំណងផ្ដល់លទ្ធភាពឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំនៅក្នុងសំណុំរឿង ០០២ រៀបរាប់អំពីការឈឺចាប់របស់ខ្លួន ហើយតាមរយៈការរៀបរាប់នេះ ពួកគាត់បានចាប់ផ្ដើមដំណើរការព្យាបាលការឈឺចាប់ដែលបានទទួលរង ព្រមទាំងដើម្បីជំរុញឲ្យមានការផ្សះផ្សាផងដែរ។

20. គម្រោងមួយនេះត្រូវបានរៀបចំឡើយដោយដាក់បញ្ចូលកិច្ចជួបប្រជុំចំនួន ៨ ដង ដោយមានក្រុមដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមនៅក្នុងនោះ ហើយក្នុងមួយខែម្ដង។ ការជួបជុំគ្នានេះនឹងមានបុគ្គលិកវិជ្ជាជីវៈមួយរូបនៅអមជាមួយ ដើម្បីធ្វើជាមគ្គុទេសក៍ដល់ពួកគេនៅក្នុងអំឡុងពេលនៃវិធីព្យាបាលមួយនេះ។ វិធីព្យាបាលជាក្រុមរួមក៏នឹងរួមបញ្ចូលកិច្ចជួបសន្ទនាបើកចំហមួយរវាងអ្នកប្រព្រឹត្ត ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះដែលជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសហគមន៍របស់ពួកគេផងដែរ។ វិធីព្យាបាលបែបនេះក៏ជាផ្នែកមួយនៃការផ្សះផ្សាដ៏មានសារៈសំខាន់ផងដែរ។

ជំពូកទី៣៖ ការចងក្រងឯកសារ និងការអប់រំ

***គម្រោងទី ៥៖ គម្រោងអប់រំ និងតាំងពិពណ៌ចល័ត (ការស្វែងយល់អំពីប្រវត្តិសាស្ត្រ និងយុត្តិធម៌អន្តរកាល)***

21. ដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមស្នើសុំឱ្យបង្កើតគម្រោងតាំងពិពណ៌ និងអប់រំ ដើម្បីអប់រំអ្នករស់រានមានជីវិត និងប្រជាជនកម្ពុជាជំនាន់ក្រោយសង្គ្រាមអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងសម័យខ្មែរក្រហម និងជាពិសេសជាងនេះ នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំ។ ដៃគូសង្គមស៊ីវិលនៅក្នុងគម្រោងនេះរួមមាន អង្គការ ក្តីករុណា និងយុវជនដើម្បីសន្តិភាព ដែលជាអ្នកអនុវត្តគម្រោង ព្រមទាំងសមាគមអាដហុក និងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលដើរតួនាទីជាអ្នកប្រឹក្សាយោបល់[7]។

22. ព័ត៌មានភាគច្រើនដែលមានក្នុងពេលបច្ចុប្បន្នស្តីពីសម័យខ្មែរក្រហមពុំអាចរកមើលបាន មានលក្ខណៈស្មុគស្មាញ និងពិបាកឱ្យប្រជាពលរដ្ឋកម្ពុជាស្វែងយល់។ ដើម្បីធ្វើឱ្យគម្រោងអប់រំនៅក្នុងផ្នែកទាំងនេះមានប្រសិទ្ធភាព គម្រោងនេះមានគោលបំណងបំពេញតម្រូវការក្នុងការស្វែងយល់អំពីអតីតកាល ជាពិសេសប្រធានបទនៃការជម្លៀសដោយបង្ខំ តាមរយៈពិធីតាំងពិពណ៌ចល័ត និងព្រឹត្តិការណ៍ចូលរួមប្តូរយោបល់គ្នា។ តាមរយៈខ្សែភាពយន្តខ្លីៗ និងសក្ខីកម្មរៀបរាប់ដោយផ្ទាល់ពីដើមបណ្តឹងរដ្ឋប្បវេណី ពិធីតាំងពិពណ៌ចល័តនេះនឹងចងក្រងទុកជាឯកសារនូវបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីការជម្លៀសដោយបង្ខំ និងព្យសនកម្មផ្សេងទៀតដែលទទួលរងនៅក្រោមរបបខ្មែរក្រហម ហើយនឹងផ្សព្វផ្សាយរឿងរ៉ាវទាំងនេះឱ្យបានទូលំទូលាយដល់សាធារណជន។ សកម្មភាពភាគច្រើននឹងធ្វើឡើងនៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជា ដោយផ្តោតគោលដៅសំខាន់លើអ្នកទទួលប្រយោជន៍ ដែលជារឿយៗពុំមានលទ្ធភាពទទួលប្រយោជន៍ពីគម្រោងស្រដៀងៗគ្នាទាំងនេះនៅថ្នាក់ជាតិ ដូចជា ពិធីតាំងពិពណ៌នានាដែលគ្រោងនឹងរៀបចំឡើងជាអចិន្ត្រៃយ៍ និងគម្រោងរំលឹកការចងចាំផ្សេងទៀតនៅក្នុងរាជធានី។

23. បទពិសោធន៍បានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនមានលទ្ធភាពប្រមូលព័ត៌មានដែលត្រូវបានបង្ហាញដោយវិធីផ្លោះប្តូរយោបល់គ្នា មានការចូលរួម និងមានគរុកោសល្យសមស្រប។ ដៃគូអនុវត្តបានយកបទពិសោធន៍ដ៏ទូលំទូលាយរបស់ខ្លួន តាមរយៈការចូលរួមរបស់សហគមន៍ កម្មវិធីផ្សព្វផ្សាយដោយមានការចូលរួម និងវគ្គអប់រំប្តូរយោបល់គ្នាមកជំរុញឱ្យមាន

---

[7] ~~ប្រសិនបើអង្គការមិនរំលងរដ្ឋាភិបាលបច់នោះ ពួកគេអាចដាក់បញ្ចូលការលើកឡើងមួយផ្លូវ ឬ ពីរស្តីពីការងាររបស់ពួកគេជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីមកទល់សព្វថ្ងៃបាន។~~

ការពិភាក្សាក្នុងចំណោមមនុស្សក្នុងជំនាន់ខុសៗគ្នាអំពីប្រធានបទនេះ ដោយភ្ជាប់បទពិសោធន៍ទាំងនេះរួមជាមួយនឹងបទពិសោធន៍នៅតាមមូលដ្ឋាន។ គម្រោងដែលត្រូវបានស្នើឡើងនឹងចូលរួមចំណែកនៅក្នុងការផ្សះផ្សា និងបញ្ចប់ការឈឺចាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត។ ក្រៅពីពិធីតាំងពិពណ៌ចល័តតាមរយៈទូរទស្សន៍ និងមធ្យោបាយព័ត៌មាននានា ព័ត៌មានបន្ថែមស្តីពីការងារនៅ អ.វ.ត.ក និងស្តីពីការជម្លៀសដោយបង្ខំ នឹងត្រូវបានផ្សព្វផ្សាយ និងផលិតឡើងស្របជាមួយគ្នានឹងព្រឹត្តិការណ៍អប់រំ។

***គម្រោងទី ៦៖ ពិធីតាំងពិពណ៌អចិន្ត្រៃយ៍***

24. ដើមបណ្តឹងរដ្ឋប្បវេណីចង់ឲ្យបង្កើតទីតាំងពិធីតាំងពិពណ៌អចិន្ត្រៃយ៍ជាសាធារណៈមួយ ដែលរួមបញ្ចូលនូវសម្ភារៈនានា ដូចជា រូបថត អដ្ឋិធាតុ ឯកសារ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នករស់រានមានជីវិតតាមរយៈមធ្យោបាយផ្សព្វផ្សាយ ការសម្តែងសិល្បៈឈុតឆាកទស្សនីយភាពស្តីពីប្រវត្តិសាស្ត្រ និងកម្មវិធីអប់រំផ្លាស់ប្តូរយោបល់គ្នាផ្សេងទៀត ក្នុងគោលបំណងរក្សាទុករឿងរ៉ាវសល់ពីសម័យខ្មែរក្រហម និងក្នុងគោលបំណងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជនអប់រំខ្លួនឯងអំពីរបបនេះ និងជាពិសេស អំពីការជម្លៀសប្រជាជនដោយបង្ខំ។

25. សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះបានចរចាជាច្រើនរួចហើយជាមួយនឹងអង្គការជាដៃគូនានា និងខំប្រឹងស្វែងរកដៃគូដែលមានសក្តានុពលសម្រាប់គម្រោងនេះ ហើយបានចាប់ផ្តើមធ្វើការចរចា និងរៀបចំ ធ្វើឲ្យភាពជាដៃគូនេះអាចកើតឡើងបង្កើតភាពជាដៃគូដ៏រឹងមាំជាផ្លូវការ។

***គម្រោងទី ៧៖ កូនសៀវភៅស្តីពីអង្គហេតុដែលត្រូវបានវិនិច្ឆ័យនៅក្នុងសំណុំរឿង ០០២/០១ និងស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី***

26. គម្រោងនេះមានគោលបំណងបង្កើតជាកូនសៀវភៅមួយស្តីពីដំណើរការជំនុំជម្រះនៅ អ.វ.ត.ក ជាពិសេស ដោយមានគោលបំណងចងក្រងទុកជាឯកសារ និងពន្យល់អំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងស្តីពីការប្រព្រឹត្តនៃការជម្លៀសដោយបង្ខំ និងឧក្រិដ្ឋកម្មផ្សេងៗ ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១។

27. កូនសៀវភៅនេះនឹងរៀបរាប់ជាក់លាក់អំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលដំណើរការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ហើយអ្វីដែលពិសេសជាងនេះគឺថា កូនសៀវភៅនេះនឹងរួមបញ្ចូលសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើឡើងនៅ

ក្នុងអំឡុងពេលសវនាការ។ នៅក្នុងចំណោមប្រធានបទផ្សេងទៀត យើងអាចពិភាក្សាអំពីផលវិបាកនៃឧក្រិដ្ឋកម្មទាំងនេះដែលកើតមានមកលើដើមបណ្តឹងរដ្ឋប្បវេណី។ ផ្នែកមួយទៀតនៅក្នុងកូនសៀវភៅនេះ នឹងមានគោលបំណងរៀបរាប់អំពីឧក្រិដ្ឋកម្មនៃការជម្លៀសដោយបង្ខំ និងអង្គហេតុផ្សេងទៀត និងផលវិបាករបស់វានៅក្នុងទម្រង់មួយដែលមនុស្សជំនាន់ៗក្រោយៗអាចស្វែងយល់បាន។

28. គម្រោងនេះគឺជាផ្នែកមួយនៃគម្រោងធំៗជាងនេះផ្សេងទៀត ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឡើងដើម្បីប្រមែប្រមូលឯកសារដែលត្រូវបានចងក្រងទុកពាក់ព័ន្ធនឹងរបបខ្មែរក្រហម និង អ.វ.ត.ក ដើម្បីចងក្រងទុកជាបណ្ណសារ និងដើម្បីបើកឱ្យសាធារណជនអាចស្វែងយល់ដើម្បីធ្វើការអប់រំប្រជាជន។

29. សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះបានចរចារជាច្រើនរួចហើយជាមួយអង្គការជាដៃគូនានា និងខិតខំកំណត់ឃើញអង្គការដៃគូរថ្មីៗដែលមានសក្តានុពលសម្រាប់គម្រោងនេះ ហើយបានចាប់ផ្តើមធ្វើការចរចារ និង រៀបចំធ្វើឱ្យភាពជាដៃគូនេះកើតឡើងជាផ្លូវការ។

## III. ស្ថានភាពនៃការរៃអង្គាសមូលនិធិសម្រាប់គម្រោងសំណងអាទិភាព (កំពុងរង់ចាំព័ត៌មានបន្ថែមពីអង្គភាពគាំពារជនរងគ្រោះដើម្បីបំពេញផ្នែកនេះ)

***ការទទួលខុសត្រូវចំពោះការរៃអង្គាសមូលនិធិ***

30. សហមេធាវីនាំមុខយល់ និងទទួលស្គាល់យ៉ាងពេញលេញថា សំណងទាំងឡាយដែលស្នើសុំអនុលោមតាមវិធាន ២៣*ក្វាទួន*(ខ) ត្រូវមានការធានាផ្នែកមូលនិធិ និងត្រូវរៀបចំឡើងសមស្របដើម្បីធ្វើយ៉ាងណាឱ្យអាចអនុវត្តទៅបាន។ យើងខ្ញុំក៏បានយល់ដឹងច្បាស់អំពីរយៈពេលដែលត្រូវការដើម្បីរៃអង្គាសមូលនិធិបែបនេះ និងភាពចាំបាច់ពុំអាចខ្វះបាននូវយុទ្ធសាស្ត្ររៃអង្គាសមូលនិធិ ដែលត្រូវបានរៀបចំផែនការត្រឹមត្រូវមាននិរន្តភាព និងមានភាពចម្រុះ។ តាមលទ្ធភាពដែលអាចធ្វើទៅបាន សហមេធាវីនាំមុខបានប្រឹងប្រែងជួយអង្គភាពគាំពារជនរងគ្រោះ និងអង្គការជាដៃគូនៅក្នុងការរៃអង្គាសមូលនិធិ។ នៅក្នុងសកម្មភាពផ្សព្វផ្សាយរបស់យើងខ្ញុំ សហមេធាវីនាំមុខបានព្យាយាមយ៉ាងខ្លាំងក្លាក្នុងការជូនដំណឹងដល់សាធារណជន និងជាពិសេសម្ចាស់ជំនួយ អំពីការងារស្តីពីសំណង និងឱកាសក្នុងការផ្តល់មូលនិធិដល់គម្រោងសំណងអាទិភាព។ ម្យ៉ាងវិញទៀត យើងខ្ញុំបានផ្តល់ការជួយជ្រោមជ្រែងដល់អង្គភាពគាំពារជនរងគ្រោះ និងអង្គការជាដៃគូ នៅក្នុង

ទម្រង់ជាលិខិតគាំទ្រជាផ្លូវការ និងការចូលរួមនៅក្នុងកិច្ចប្រជុំដើម្បីពន្យល់អំពីរបបសំណងនៅ អ.វ.ត.ក អត្ថន័យនៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីបន្ថយការព្រួយបារម្ភរបស់អ្នកដែលអាចជាម្ចាស់ជំនួយដែលត្រូវបានគេរាយការណ៍ថាមាន ការព្រួយបារម្ភពាក់ព័ន្ធនឹងភាពត្រឹមត្រូវផ្នែកច្បាប់ និងលទ្ធភាពអនុវត្តសំណងតាមផ្លូវច្បាប់។ យើងខ្ញុំក៏បានព្យាយាមសម្របសម្រួលការចរចារវាងអង្គភាពគាំពារជនរងគ្រោះ និងអង្គការជាដៃគូ ស្តីពីបញ្ហានៃការរៃអង្គាសមូលនិធិ និងការផ្តល់ហិរញ្ញប្បទាន ដើម្បីឲ្យកិច្ចប្រឹងប្រែងលើការរៃអង្គាសមូលនិធិអាចដំណើរការទៅមុខបាន។ ចំណុចចុងក្រោយ យើងខ្ញុំក៏បានព្យាយាមរៀបចំគម្រោងដ៏មានអត្ថន័យ ដោយមានវិសាលភាព និងការចំណាយសមស្រប និងឆ្លើយតបទៅនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ទោះបីជាយ៉ាងនេះក្តី សហមេធាវីនាំមុខក៏សូមគូសបញ្ជាក់ផងដែរថា កិច្ចប្រឹងប្រែងរបស់យើងខ្ញុំគ្រាន់តែជាការគាំទ្រ ការសម្របសម្រួល និងការជួយជ្រោមជ្រែងនៅក្នុងផ្នែកសំណងប៉ុណ្ណោះ។ យើងខ្ញុំពុំមានជំនាញ ឬអំណាចក្នុងការទទួលខុសត្រូវដោយ ផ្ទាល់លើការរៃអង្គាសមូលនិធិឡើយ។

31. ម្យ៉ាងវិញទៀត អង្គភាពគាំពារជនរងគ្រោះអាចមានលទ្ធភាពប្រសើរជាងយើងខ្ញុំនៅក្នុងការអនុវត្តការងារដ៏សំខាន់នេះ។ យ៉ាងហោចណាស់ កាលពីឆ្នាំមុន អង្គភាពគាំពារជនរងគ្រោះមានបុគ្គលិកពីររូបបំពេញតែការងារស្តីពីសំណង និងវិធានការក្រៅតុលាការប៉ុណ្ណោះ។ យើងខ្ញុំយល់ឃើញថាបុគ្គលទាំងពីររូបនេះមានការទទួលខុសត្រូវចំបងនៅក្នុងការរៃអង្គាសមូលនិធិសម្រាប់សំណងដែលស្នើសុំអនុលោមតាមវិធាន ២៣*ស្ទួនបួន* (ខ)។

### *កិច្ចប្រឹងប្រែងដែលត្រូវបានធ្វើឡើង និងស្ថានភាពហិរញ្ញវត្ថុរបស់គម្រោង*

32. នៅក្នុងអំឡុងឆ្នាំ ២០១២ អង្គភាពគាំពារជនរងគ្រោះបានរៀបចំឯកសារមួយចំនួនពាក់ព័ន្ធនឹងការរៃអង្គាសមូលនិធិ ដោយរួមមានសេចក្តីសង្ខេបការកម្មវិធីសំណងនៅ អ.វ.ត.ក[8] សេចក្តីរៀបរាប់

[8] ឧបសម្ព័ន្ធA<u>“កម្មវិធីសំណង២០១៣-២០១៧ របស់អង្គភាពគាំពារជនរងគ្រោះ”</u> ~~–XXX~~។ នេះជាសេចក្តីសង្ខេបនៃឯកសារធំមួយដែលរៀបរាប់អំពីទស្សនវិស័យរបស់អង្គភាពគាំពារជនរងគ្រោះស្តីពីសំណង ( ដែលត្រូវបានគេយល់យ៉ាងទូលំទូលាយថារួមបញ្ចូលទាំងសំណងតាមផ្លូវតុលាការ និងវិធានការក្រៅតុលាការ ដូចបានរៀបរាប់នៅក្នុងតុលាការនេះ) នៅក្នុងពេលបច្ចុប្បន្ន និងក្រោយពេល អ.វ.ត.ក បានបញ្ចប់អាណត្តិការងាររបស់ខ្លួន។

គម្រោងមួយទំព័រ[9] និងយុទ្ធសាស្ត្រតស៊ូមតិ និងរៃអង្គាសមូលនិធិ[10]។ ចំពោះឯកសារពីរដំបូងនេះ សហមេធាវីនាំមុខ បានស្នើសុំឱកាសនៅក្នុងការផ្តល់មតិយោបល់តបទៅនឹងឯកសារទាំងពីរនេះ ហើយបានទទួលជោគជ័យនៅក្នុងការចរចាឱ្យមានការកែប្រែខ្លះៗលើខ្លឹមសារជាច្រើន បើទោះជាពុំមានការកែប្រែទាំងស្រុងទៅតាមសំណើសុំក៏ដោយ។ ខ្លឹមសារពាក់ព័ន្ធនឹងការរៀបចំ និងផ្នែកនៃគម្រោងទាំងនេះ ត្រូវបានដកស្រង់ចេញពីការបញ្ជាក់ជាលាយលក្ខណ៍អក្សរ ដែលត្រូវបានរៀបចំឡើងដោយផ្នែកសហមេធាវីនាំមុខ ក៏ប៉ុន្តែ ខ្នង់ថវិកាត្រូវបានកំណត់ដោយអង្គភាពគាំពារជនរងគ្រោះ។ នៅក្នុងពេលបច្ចុប្បន្ន ខ្នង់ថវិកានេះកំពុងត្រូវបានវាយតម្លៃឡើងវិញនៅក្នុងដំណើរការរៀបចំគម្រោងចុងក្រោយនេះ ហើយសហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជឿជាក់ថា យ៉ាងហោចណាស់ខ្នង់ថវិកាខ្លះនឹងត្រូវជាកម្មវត្ថុនៃការពិភាក្សា និងកែប្រែទៅថ្ងៃមុខ~~ជាមួយអង្គភាពគាំពារជនរងគ្រោះ~~[11]។

33. នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ សហមេធាវីនាំមុខបានស្នើសុំឱ្យអង្គភាពគាំពារជនរងគ្រោះផ្តល់ព័ត៌មានលម្អិតស្តីពីសកម្មភាពនៃការរៃអង្គាសមូលនិធិរបស់ខ្លួន[12]។ ជាការឆ្លើយតប សហមេធាវីនាំមុខបានទទួលពីអង្គភាពជនរងគ្រោះនូវ "របាយការណ៍ស្តីពីស្ថានភាពគម្រោង"[13] ដែលលើកឡើងថាពុំទាន់មានការធានាមូលនិធិសម្រាប់សំណងនោះទេមកទល់នឹងពេលនេះ ឯកសារកម្មវិធី

---

[9] ឧបសម្ព័ន្ធ B "សេចក្តីលំអិតអំពីគម្រោងអាទិភាពទាំង៦របស់អង្គភាពគាំពារជនរងគ្រោះ"~~XXX~~។ ឯកសារនេះត្រូវបានកែសម្រួលដោយអង្គភាពគាំពារជនរងគ្រោះនៅក្នុងខែ មករា ឆ្នាំ ២០១៣ ហើយ ក្នុងពេលបច្ចុប្បន្ន ត្រូវបានដាក់ចំណងជើងថា "គម្រោងជាអាទិភាព"។ ឯកសារនេះរួមបញ្ចូលតែការពិពណ៌នាអំពីគម្រោងសំណងអាទិភាពប៉ុណ្ណោះ។

[10] ឧបសម្ព័ន្ធ C ការតស៊ូមតិក្នុងការរៃអង្គាសមូនិធិរបស់អង្គភាពគាំពារជនរងគ្រោះ"~~XX~~។

[11] ត្រង់ចំណុចនេះ យើងខ្ញុំសូមស្នើថា ថវិកាសម្រាប់គម្រោងទិវារំលឹកការចងចាំ ពិធិតាំងពិពណ៌អចិន្ត្រៃយ៍ និងជំពូកសៀវភៅអាចត្រូវបានកាត់បន្ថយយ៉ាងច្រើន ខណៈពេលដែលនៅតែរក្សាផ្នែកចំបងៗដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី។

[12] សូមមើល ឧបសម្ព័ន្ធ Dឃ៖ លិខិតពីសហមេធាវីនាំមុខផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ ដែលស្នើសុំព័ត៌មានបច្ចុប្បន្នភាពនៃសកម្មភាពរៃអង្គាសមូលនិធិរបស់អង្គភាពគាំពារជនរងគ្រោះ ចុះថ្ងៃទី១០ មករា ២០១៣។ សារណាឆ្លងផ្នែកជាបន្តបន្ទាប់ (សូមមើល ឧបសម្ព័ន្ធ Eង) ចុះថ្ងៃទី ២២ មករា ២០១៣ត្រូវបានផ្ញើរចេញដើម្បីស្នើសុំទៅអង្គភាពគាំពារជនរងគ្រោះអោយផ្តល់សេចក្តី លម្អិតបន្ថែមទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងរកជំនួយដែលត្រូវបានស្នើសុំតាំងពីដំបូង ប៉ុន្តែមិនត្រូវបញ្ចូលក្នុងរបាយការណ៍ ស្តីពី ស្ថានភាពគម្រោងទាំងអស់។ សេចក្តីលម្អិតបន្ថែមទាំងនេះមិនទាន់បានផ្តល់មកសហមេធាវីនាំមុខទេ នៅខណៈពេលដែលសារណានេះត្រូវបានផ្ញើរចេញទៅអង្គភាពបកប្រែ។

[13] ឧបសម្ព័ន្ធ Fច៖ របាយការណ៍ស្តីពីស្ថានភាពគម្រោងសំណងរបស់អង្គភាពគាំពារជនរងគ្រោះ សម្រាប់សហមេធាវីនាំមុខ ចុះថ្ងៃ ទី២០ មករា ២០១៣។ ។

សំណងនៃ អ.វ.ត.ក. លិខិតពន្យល់ភ្ជាប់ជាមួយនឹងបញ្ជីម្ចាស់ជំនួយសក្តានុពល ដែលចងក្រង ដោយអង្គភាពគាំពារជនរងគ្រោះ ដែលក្នុងនោះមានម្ចាស់ជំនួយចំនួន[14]។ ឯកសារទាំងឡាយដែល អង្គភាពគាំពារជនរងគ្រោះរៀបចំឡើងនៅក្នុងឆ្នាំ ២០១២ គឺជាឯកសារដែលអង្គភាពគាំពារជនរង គ្រោះប្រើប្រាស់នៅក្នុងកិច្ចប្រែងប្រែងរបស់ខ្លួននៅក្នុងការរៃអង្គាសមូលនិធិ។

34. សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាមូលនិធិត្រូវតែ មានការធានាសម្រាប់គម្រោងសំណងជាអាទិភាព ដោយផ្អែកលើមូលដ្ឋានបន្ទាន់ និងជាអាទិភាព។ យុទ្ធិសាស្ត្ររៃអង្គាសមូលនិធិរបស់អង្គភាពគាំពារជនរងគ្រោះបច្ចុប្បន្ន មានរួមបញ្ចូលការបង្កើត មូលនិធិជនរងគ្រោះកម្ពុជា (VFC) ជាយន្តការសក្តានុពលសម្រាប់កំណត់ទិសដៅ និងគ្រប់គ្រង មូលនិធិសម្រាប់គម្រោងសំណង។ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋ ប្បវេណីកពុងពិភាក្សាអំពីតួនាទីដែល VFC (វិធានការណ៍ក្រៅបច្ចេកទេសតុលាការ) អាចបំពេញ ក្នុងការផ្តល់ហិរញ្ញបទានដល់គម្រោងសំណង ប៉ុន្តែពួកគាត់ទទួលស្គាល់ថា ប្រសិនបើមានការយល់ ព្រមពីម្ចាស់ជំនួយ គម្រោងសំណងក៏អាចនឹងត្រូវបានផ្តល់មូលនិធិ និងអនុវត្តដោយផ្ទាល់ជាមួយ អង្គការជាដៃគូនានាផងដែរ។

35. បន្ថែមពីលើការព្យាយាមកំណត់ខ្ទង់ថវិកាចុងក្រោយ ឲ្យបានទាបជាងមុនចំពោះគម្រោងជា អាទិភាពមួយចំនួននោះ បើអាចធ្វើទៅបានត្រូវពិចារណាឲ្យបានហ្មតចត់ទៅលើវិសាលភាព គម្រោង ដោយធ្វើយ៉ាងណាឲ្យថាប្រសិនបើការផ្តល់មូលនិធិអាចធានាបានសម្រាប់តែផ្នែក មូលដ្ឋាន និងផ្នែកសំខាន់ៗ នោះគម្រោងទាំងនេះនឹងអាចដំណើរការទៅមុខទៅតាមនេះ ហើយ ប្រសិនបើមូលនិធិបន្ថែមអាចទទួលបាន ផ្នែកបន្ថែមផ្សេងទៀតអាចត្រូវបានដាក់បញ្ចូលនៅក្នុង ពេលទាមទារសំណងចុងក្រោយ ឬនៅក្នុងដំណាក់កាល ក្រោយៗនៃគម្រោង។ វិធីសាស្ត្រទាំងនេះ នឹងបើកលទ្ធភាពឲ្យមានវិធីសាស្ត្របត់បែនជាងមុនមួយនៅក្នុងការរៃអង្គាសមូលនិធិ សម្រាប់ គម្រោងទាំងនេះ។ ជាការពិត កិច្ចប្រឹងប្រែងរបស់ អង្គភាពគាំពារជនរងគ្រោះ សហមេធាវីនាំមុខ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គការជាដៃគូនៅក្នុងការងារនេះ ត្រូវធានានូវ

[14] អង្គភាពគាំពារជនរងគ្រោះបានផ្តល់បញ្ជីម្ចាស់ជំនួយសក្តានុពលចំនួន កៅសិបប្រាំមួយ (៩៦) ដែលត្រូវបានបែងចែកជា ប្រភេទរដ្ឋាភិបាល និងភ្នាក់ងារ ក្រុមហ៊ុនមូលនិធិ និងម្ចាស់ជំនួយជាបុគ្គលឯកជន។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទាមទារ សេចក្តីលម្អិតបន្ថែមអំពីបញ្ជីនេះ ផ្នែកសហមេធាវីនាំមុខអាចដាក់បញ្ជីនេះជាឧបសម្ព័ន្ធសម្ងាត់បំផុតរបស់សារណានេះ។

ចំណុចសំខាន់ថា គម្រោងសំណងត្រូវមានអត្ថន័យ និងមានប្រសិទ្ធភាពនៅក្នុងការជួសជុលព្យសនកម្មទាំងឡាយដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង។

## សេចក្ដីសន្និដ្ឋាន

36. សហមេធាវីនាំមុខបានដាក់បញ្ចូលគម្រោងសំណងជាអាទិភាពចំនួន ៧ នៅក្នុងសេចក្ដីសន្និដ្ឋាននេះ ហើយបានផ្ដល់បច្ចុប្បន្នភាពអំពីកិច្ចប្រឹងប្រែងនៅក្នុងការរៃអង្គាសមូលនិធិ ដោយអង្គភាពគាំពារជនរងគ្រោះ។ លើសពីនេះ យើងខ្ញុំក៏បានផ្ដល់ព័ត៌មានលម្អិតបន្ថែមស្ដីពីលក្ខណៈ គោលបំណង និងស្ថានភាពនៃគម្រោងទាំងនេះផងដែរ។ ការកំណត់ និងការរៀបចំគម្រោងទាំងនេះគឺស្ថិតនៅក្នុងដំណាក់កាលវិវត្តទៅមុខ ប៉ុន្ដែទោះជាយ៉ាងណាក៏ដោយ ការធានាផ្នែកហិរញ្ញវត្ថុមិនទាន់មាននៅឡើយទេ។ ប្រសិនបើមានក៏មិនទាន់ច្បាស់លាស់នៅឡើយ។ សហមេធាវីនាំមុខ និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះព្រមទាំងអង្គការអន្ដរការី នឹងខិតខំសហការដើម្បីបញ្ចប់ការរៀបចំគម្រោងអាទិភាព ហើយយើងខ្ញុំនឹងផ្ដល់ការគាំទ្រនៅក្នុងកិច្ចប្រឹងប្រែងនៅក្នុងការរៃអង្គាសមូលនិធិផងដែរ។ យើងខ្ញុំសូមលើកឡើងសារជាថ្មីម្ដងទៀតថា ការដាក់ជាអាទិភាពនេះពុំរាំងលទ្ធភាពនៅក្នុងការដាក់បញ្ចូលគម្រោងផ្សេងទៀត នៅក្នុងការទាមទារសំណងចុងក្រោយ អនុលោមតាមវិធាន ៨០*ស្ទួន*(៤) នៃវិធានផ្ទៃក្នុងជូនអង្គជំនុំជម្រះសាលាដំបូងឡើយ ប្រសិនបើគម្រោងអាទិភាពទាំងនេះត្រូវបានបង្កើតឡើង និងត្រូវបានផ្ដល់មូលនិធិគ្រប់គ្រាន់នោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ១២ កុម្ភៈ | ពេជ អង្គ | ភ្នំពេញ | |

00888457

| | | | |
|---|---|---|---|
| ២០១៣ | សហមេធាវីនាំមុខជាតិ | | |
| | Elisabeth SIMONNEAU-FORT សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |